# បទអន្តរាគមន៍
# ស្តីពីការគ្រប់គ្រងថវិការដ្ឋ
# សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៥ និងលើកទិសដៅការងារឆ្នាំ ២០១៦
# របស់ក្រសួងអភិវឌ្ឍន៍ជនបទ
# ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៦
# ដោយលោក ឆាន សុម៉ារ៉ា ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ

## ១. សេចក្តីផ្តើម

កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមាននៅក្នុងគោលនយោបាយយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលអាណត្តិទី ៥ មានគោលបំណងដើម្បីគ្រប់គ្រង និងប្រើប្រាស់ថវិការដ្ឋប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ។ ដោយមើលឃើញពីចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង់ថវិកាឲ្យមាន ប្រសិទ្ធភាពក្រសួងអភិវឌ្ឍន៍ជនបទដែលមាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ ជាសេនាធិការ បាននិងកំពុងខិតខំអនុវត្តផែនការយុទ្ធសាស្រ្តថវិកាអោយបានសមស្របពង្រឹងការរៀបចំថវិកាអោយបានគ្រប់ជ្រុងជ្រោយ និងសុក្រឹតស្របតាមកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ពិសេសគឺបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ដើម្បីរួមចំណែកលើកស្ទួយដល់ការគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ ដែលជាស្នូលនៃយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

## ២. តួនាទី និងភារកិច្ច

នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុជាសេនាធិការផ្ទាល់របស់ **ឯកឧត្តមរដ្ឋមន្ត្រី** ក្នុងការអនុវត្តដំណើរការនៃការងារគ្រប់គ្រងប្រើប្រាស់ថវិការដ្ឋ របស់ក្រសួងដូចជា ÷

- រៀបចំផែនការយុទ្ធសាស្រ្តថវិកាប្រចាំឆ្នាំ
- រៀបចំកញ្ចប់ថវិកាកម្មវិធី តាមជំពូក តាមគណនី និងអនុគណនី
- ត្រួតពិនិត្យការងារហិរញ្ញវត្ថុ ឲ្យស្របតាមនីតិវិធីហិរញ្ញវត្ថុ
- ត្រួតពិនិត្យបច្ចេកទេសនៃប្រតិបត្តិការកិច្ចលទ្ធកម្មសាធារណ:
- គ្រប់គ្រងថវិការដ្ឋ

- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភ័ណ្ឌ

## ៣. ស្ថានភាពនាយកដ្ឋាន

### ៣.១ យុទ្ធសាស្ត្រនៃការគ្រប់គ្រង

ថ្នាក់ដឹកនាំ និងមន្ត្រីក្នុងនាយកដ្ឋានទាំងអស់មានភាពសាមគ្គីផ្ទៃក្នុង និងមានកិច្ចសហការគ្នាបានល្អ ក្នុងការបំពេញការងារដោយយកចិត្តទុកដាក់ និងខិតខំប្រឹងប្រែងអនុវត្តប្រកបដោយភាពរលូន និងទទួលបានលទ្ធផលល្អជាទីមោទនភាពបំផុត។

វិធីសាស្ត្រនៃការគ្រប់គ្រងធនធានមនុស្ស របស់នាយកដ្ឋានមានដូចខាងក្រោម÷

- ខិតខំលើកទឹកចិត្តមន្ត្រី ឱ្យយកចិត្តទុកដាក់ និងខិតខំអនុវត្តការងារយ៉ាងសកម្ម
- ចាត់ចែងអនុវត្តការងារតាមតួនាទី ភារកិច្ច ចំណេះដឹងជំនាញនិងទេពកោសល្យរបស់មន្ត្រីម្នាក់ៗ
- កែលម្អកន្លែងធ្វើការ និងផ្គត់ផ្គង់ឧបករណ៍-សម្ភារៈ ជូនមន្ត្រីគ្រប់រូបបានសមរម្យ និងតាមតម្រូវការជាក់ស្តែង
- ពង្រឹងបន្ថែមនូវចំណេះដឹងជំនាញដល់មន្ត្រីក្រោមឱវាទ តាមរយៈការបញ្ជូនឱ្យទៅសិក្សាបន្ថែម ដូចជា វគ្គបណ្តុះបណ្តាលកុំព្យូទ័ររយៈពេលខ្លី និងវគ្គបណ្តុះបណ្តាលជំនាញរៀបចំដោយអង្គការដៃគូអភិវឌ្ឍន៍នានា...។

## ៤. លទ្ធផលការងារសម្រេចបានក្នុងឆ្នាំ ២០១៥

ដើម្បីចូលរួមចំណែកអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ បានខិតខំប្រឹងប្រែងចូលរួមចំណែកយ៉ាងសកម្មក្នុងការជំរុញការងារ ការដ្ឋានកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។ ជាលទ្ធផលសម្រេចបានក្នុង ឆ្នាំ ២០១៥ នាយកដ្ឋានផ្គត់ផ្គង់ និង ហិរញ្ញវត្ថុសម្រេចបាននូវភាពជោគជ័យជូនក្រសួងអភិវឌ្ឍន៍ជនបទ លើការងារសំខាន់ៗមួយចំនួនរួមមាន÷

### ៤.១ ច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងថវិកាឆ្នាំ ២០១៥ ធៀបនឹងឆ្នាំ ២០១៤

នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ សហការជាមួយនាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ ដើម្បីរៀបចំផែនការថវិការដ្ឋឆ្នាំ ២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទមានទិសដៅជាយុទ្ធសាស្ត្រកំណត់ចំណាយថវិកាសរុបចំនួន 284.495.368.000 រៀលគឺមានកំណើន 1.43% ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០១៤ ។

ថវិការដ្ឋរបស់ក្រសួងឆ្នាំ ២០១៥ ត្រូវបែងចែកតាមជំពូកសំខាន់ៗ ដូចក្នុងតារាងខាងក្រោម÷

- ជំពូក ៦០ ការទិញ គឺការទិញសម្ភារសម្រាប់ការងារថៃទាំទាំងឡាយ ដែលអនុវត្តដោយស្ថាប័នរដ្ឋ ចំណាយលើសម្ភារៈផ្គត់ផ្គង់រដ្ឋបាល ស្បៀងអាហារ ការតុបតែង និងការប្រើប្រាស់ថាមពល និង

ទឹក មានចំនួន 9,551,131,200 រៀល គឺថយចុះ 14,27% ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០១៤

- ជំពូក ៦១ សេវាខាងក្រៅ គឺចំណាយលើសេវាខាងក្រៅ ដូចជាការជួលមធ្យោបាយដឹកជញ្ជូន ថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម) សោហ៊ុយបណ្តុះបណ្តាលបុគ្គលិកក្នុង និងក្រៅប្រទេសការថែទាំ និងជួសជុល ។ល។ មានចំនួន 76,347,868,800 រៀល គឺមានកំណើន 46,00% ធៀបនឹង ច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០១៤
- ជំពូក ៦៤ បន្ទុកបុគ្គលិក គឺចំណាយលើបន្ទុកបុគ្គលិក ដូចជាបៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ ប្រាក់ឧបត្ថម្ភនិវត្តជន លាភការ រង្វាន់ផ្សេងៗ និងប្រាក់វិភាជន៍សង្គម សម្រាប់អំណាចសាធារណៈបុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ បុគ្គលិកមិនមែនក្របខ័ណ្ឌ និង បុគ្គលិកអណ្តែតដែលមានទិដ្ឋាការពីរដ្ឋលេខាធិការមុខងារសាធារណៈមានចំនួន 8,446,368,000 រៀល គឺមានកំណើន 48,74% ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ គ្រប់គ្រងឆ្នាំ ២០១៤
- ជំពូក ៦៣ ពន្ធ និងអាករ គឺចំណាយលើបន្ទុកពន្ធ និងអាករ ដូចជាលតាប័ត្រ និងបន្ទុកពន្ធប្រថាប់ត្រា មានចំនួន 150,000,000 រៀល គឺមានកំណើន 25,00% ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០១៤
- ជំពូក ២១ ចំណាយមូលធន គឺគម្រោងវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក មានចំនួន 190,000,000,000 រៀល គឺថយចុះ 7,32% ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០១៤ ។

### ៤.២ លទ្ធផលសម្រេចបានក្នុងការអនុវត្តថវិកាឆ្នាំ ២០១៥

ដោយមានកិច្ចសហការយ៉ាងល្អ ពីបណ្តានាយកដ្ឋានជំនាញរបស់ក្រសួង មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ទាំងប្រាំបី។ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ សម្រេចបាននូវការងារសំខាន់ៗមួយចំនួនដូចខាងក្រោម÷

ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងឆ្នាំ ២០១៥ ទទួលបានថវិកាសរុបចំនួន 284,495,368,000 រៀល ។ សរុបចំណាយរបស់ក្រសួងអនុវត្តបានចំនួន 273,642,709,227 រៀល ស្មើនឹង 96,19% នៃផែនការ ។

### ក. ចំណាយចរន្តថវិការបស់ក្រសួង

សរុបចំណាយចរន្តរបស់ក្រសួង អនុវត្តបានចំនួន 88,125,831,557 រៀល ស្មើនឹង 93,26% ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០១៥ ។

- ជំពូក ៦០ ការទិញ គឺអនុវត្តបានចំនួន 8,406,310,110 រៀលស្មើនឹង 883% ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០១៥

- ជំពូក ៦១ សេវាខាងក្រៅ គឺ អនុវត្តបានចំនួន 73,867,520,881 រៀល ស្មើនឹង 96,75% ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០១៥
- ជំពូក ៦៤ បន្ទុកបុគ្គលិក គឺ អនុវត្តបានចំនួន 5,787,640,066 រៀល ស្មើនឹង 68,52% ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០១៥
- ជំពូក ៦៣ ពន្ធនិងអាករ គឺ អនុវត្តបានចំនួន 64,360,500 រៀល ស្មើនឹង 42,01% ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០១៥

**ខ. ចំណាយមូលធន**

ចំណាយមូលធន អនុវត្តបានចំនួន 190,000,000,000 រៀល ស្មើនឹង 97,64% ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០១៥។

**គ. ចំណាយថវិកាតាមកម្មវិធី ( នាយកដ្ឋានអនុវត្តដោយផ្ទាល់ )**

ក្នុងគម្រោងចំណាយថវិកាកម្មវិធីឆ្នាំ ២០១៥ នេះ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ មានថវិកាកម្មវិធីសរុបចំនួន 6,004,900,000 រៀល បានអនុវត្តសម្រេចបានលទ្ធផល ១០០% ទៅលើគម្រោងចំនួន ០៥ រួមមាន ÷

- ផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធី
- ផ្សព្វផ្សាយលទ្ធផលសន្និតបូកសរុបការងារឆ្នាំ ២០១៤ និងទិសដៅការងារឆ្នាំ ២០១៥
- ការពង្រឹងសមត្ថភាពការអនុវត្តរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធី
- ការផ្គត់ផ្គង់សម្ភារៈ និងបរិក្ខាបច្ចេកទេស
- ពង្រឹងសមត្ថភាពការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ

សរុបមក សមិទ្ធផលដែលសម្រេចបានដូចរៀបរាប់ខាងលើនេះ មានលទ្ធផលល្អគួរជាទីមោទនគឺកើតឡើង ក្រោមការចង្អុលបង្ហាញ និងភាពដឹកនាំដ៏ត្រឹមត្រូវរបស់ **ឯកឧត្តម ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ។

**៥. បញ្ហាប្រឈមក្នុងការអនុវត្តការងារ**

ក្នុងការអនុវត្តតាមទិសដៅការងារឆ្នាំ ២០១៥ ស្របតាមទិសដៅការងាររបស់ក្រសួង និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលនីតិកាលទី ៤ នេះ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម :

- ការអនុវត្តថវិកាកម្មវិធីរបស់នាយកដ្ឋានមួយចំនួន មានការលំបាកបែបបទ និងនីតិវិធីលទ្ធកម្ម
- ការផ្តល់ធានាចំណាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើថវិកាកម្មវិធី មានភាពយឺតយ៉ាវ ។

**៦- ផែនការ និងទិសដៅសម្រាប់អនុវត្ត ឆ្នាំ ២០១៦**

ដើម្បីកាត់បន្ថយ និងដោះស្រាយនូវបញ្ហាប្រឈមខាងលើប្រកបដោយលក្ខណៈជាប្រព័ន្ធ នាយក

ដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ បាននិងកំពុងបន្តជំរុញការពង្រឹង និងពង្រីកការងារតាមរយៈរៀបចំយុទ្ធសាស្ត្ររយៈពេលវែងដូចខាងក្រោម ៖

- ប្រកាន់យកយន្តការដែលធានាតម្លាភាព និងប្រសិទ្ធភាពក្នុងក្របខណ្ឌកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ
- បន្តជំរុញការអនុវត្ត ផែនការយុទ្ធសាស្ត្រថវិកា ឲ្យបានសមស្រប ដើម្បីធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ហើយពង្រឹងការរៀបចំថវិកាឲ្យបានគ្រប់ជ្រុងជ្រោយ និងសុក្រឹត ដើម្បីកាត់បន្ថយជាអតិបរិមានូវចំណាយមិនបានគ្រោងទុក សំដៅបំបាត់ចំណាយក្រៅគម្រោងថវិកា ជាពិសេសការធ្វើនិយ័តកម្មឥណទានថវិកា និងចំណាយមិនចាំបាច់ ដើម្បីសម្រេចបាននូវការគ្រប់គ្រងថវិការដ្ឋ ប្រកបដោយប្រសិទ្ធភាព និងប្រកបដោយភាពជឿទុកចិត្ត
- បន្តជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ ឲ្យមានប្រសិទ្ធភាព
- បន្តជំរុញធ្វើការកំណត់នូវកញ្ចប់ថវិកា ក្នុងការរៀបចំគម្រោងចំណាយ ទៅតាមប្រភេទ និងជំពូក ដោយលំអិតទៅតាមគណនី និងអនុគណនី តាមនាយកដ្ឋាន និងអង្គភាព ដែលចំណុះឲក្រសួង ដើម្បីបម្រើឲ្យតម្រូការជាក់ស្តែង ក្នុងការអនុវត្តន៍កម្មវិធីសកម្មភាពចាំបាច់
- បន្តអនុវត្ត និងពង្រឹងការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យរដ្ឋ
- បន្តពង្រឹង និងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញ ឲ្យមានសមត្ថភាពពេញលេញ ក្នុងការអនុវត្តការងារ ជាពិសេសការអនុវត្តថវិកាតាមកម្មវិធី
- បន្តការតាមដាន និងការត្បិតត្បៀតចំណាយចរន្ត ជាពិសេស បន្តការសន្សំសំចៃលើមុខសញ្ញាចំណាយ ប្រេងឥន្ធនៈ អគ្គិសនី ទឹកស្អាត និងទូរស័ព្ទ ។

## ៧. សំណូមពរ

ដើម្បីឲ្យការអនុវត្ត និងការទូទាត់ថវិកាតាមកម្មវិធី ប្រព្រឹត្តទៅប្រកបដោយភាពរលូន ប្រសិទ្ធភាព និងត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ សូមសំណូមពរដល់នាយកដ្ឋាន និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ដូចខាងក្រោម ÷

- នៅពេលទទួលបានថវិកាបុរេប្រទាន ត្រូវធ្វើយ៉ាងណា យកថវិកានេះទៅអនុវត្តកម្មវិធីរបស់ខ្លួន រួចផ្តល់ឯកសារទូទាត់ឱ្យបានទាន់ពេល តាមការកំណត់របស់នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ។
- ក្នុងឆ្នាំ ២០១៥ នេះ ត្រូវរៀបចំគម្រោងចំណាយឆ្នាំ ២០១៦ និងបញ្ជូនមកនាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុឱ្យបានទាន់ពេលវេលា
- ក្នុងករណីដែលពុំទាន់បានប្រគល់ឯកសារទូទាត់ត្រឹមត្រូវនោះ នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុនឹងមិនអនុញ្ញាតផ្តល់ជូនថវិកាសម្រាប់ជុំបន្តឡើយ

- គ្រប់នាយកដ្ឋាន ខិតខំកសាងឯកសារទូទាត់ ឲ្យបានទាន់ពេលវេលា និងមានតម្លាភាព ។

**៨. សេចក្តីសន្និដ្ឋាន**

លទ្ធផលដែលទទួលបានខាងលើ យើងអាចប្រសិទ្ធិនាមថវិកាឆ្នាំ ២០១៤ នេះថា ជាថវិកាសម្រាប់បន្តលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមជនបទ ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជានៅទូទាំងប្រទេស ។

ថវិកាឆ្នាំ ២០១៥ ក៏ជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច ដែលក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំផែនការកម្មវិធីចំនួន ០៣ គឺ (១) កសាង និងលើកកម្ពស់សមត្ថភាពមន្ត្រី (២) ស្តារ កសាង និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និង (៣) លើកកម្ពស់សុខភាព អនាម័យ និងសេដ្ឋកិច្ចជនបទ ។

ថវិកាឆ្នាំ ២០១៥ គឺពិតជាឧបករណ៍គោលនយោបាយដ៏សំខាន់ សម្រាប់អនុវត្តបន្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាពិសេស ដើម្បីគាំទ្រការជំរុញការបន្តអនុវត្ត យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឆ្ពោះទៅសម្រេចឲ្យបាននូវការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍវិបុលភាព ព្រមទាំងភាពសុខដុមរមនា និងសុភមង្គល របស់ប្រជាជនកម្ពុជា។